អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

| | |
|---|---|
| **សកម្មភាព** | ៖ ល្បែង និទានសៀវភៅ |
| | **ភាសាខ្មែរ** |
| | ប្រើពាក្យសម្ដីកាយវិការ និងនិមិត្តសញ្ញាដើម្បីទំនាក់ទំនង (ការទំនាក់ទំនងដោយប្រើពាក្យសម្ដី) |
| **គោលបំណង** | ៖ |
| **(ភាសាខ្មែរ)** | ប្រាប់បានពីចំណងជើងរឿង និងអត្ថន័យរឿងតាមរូបភាព។ |
| **កម្រិតសិក្សា** | ៖ ទាប មធ្យម ខ្ពស់ |
| **រយៈពេល** | ៖ ៣០ នាទី |
| **ឧបករណ៍** | ៖ សៀវភៅរឿងនិទាន (និទានរឿងអ្វីក៏បានដែរ) |
| **ការរៀបចំ** | ៖ អានសៀវភៅត្រៀមទុកមុន៣ទៅ៤ដងសិន ដើម្បីឱ្យបានស្គាល់សាច់រឿងនៅក្នុងសៀវភៅរឿងឱ្យបានច្បាស់ជាមុនសិន។ |

**សេចក្ដីណែនាំ ៖**

1. បង្ហាញសៀវភៅ និងក្របសៀវភៅទៅកាន់ក្មេងៗក្នុងថ្នាក់
2. បង្ហាញក្របសៀវភៅ នឹងសួរសំណួរខ្លះៗដែលមាននៅលើក្របសៀវភៅរឿង និងសំណួរដែលពាក់ព័ន្ធគ្នាផងដែរ។
3. និយាយពីរបៀបនៃការថែទាំសៀវភៅ និងសំណួរផ្សេងទៀតដែលទាក់ទងនឹងការបែកសៀវភៅ និងការប្រើប្រាស់សៀវភៅឲ្យមានរបៀបជាដើម
4. ចាប់ផ្ដើមនិទានរឿងដោយបង្ហាញរូបភាពឱ្យបានច្បាស់ៗ និងយឺតៗផងដែរ
5. ចាប់ផ្ដើមសួរសំណួរដែលអ្នកបានត្រៀមទុកទាំងនោះ
   ឧ. សំណួរដែលអ្នកត្រៀមសួរ
   - ☐ តើមករា និងរតនាបានធ្វើអ្វីនៅក្នុងថ្ងៃចន្ទ?
   - ☐ តើរ៉ូបរបស់រតនាមានពណ៌អ្វី?
   - ☐ តើថ្ងៃទី២នៃថ្ងៃចូលឆ្នាំគេហៅថាថ្ងៃអ្វី?

6. ឆ្លើយសំណួរខ្លះៗដែលក្មេងៗបានសួរសំណួរ
7. អ្នកអាចសួរសំណួរអ្វីក៏បានដែរឲ្យតែទាក់ទងទៅនឹងសៀវភៅរឿងដែលបាននិទានខាងលើ
8. នៅពេលដែលនិទានរឿង អ្នកក៏អាចប្រើវិធីសាស្ត្រសួរសំណួរកុមារបណ្ដើនិទានបណ្ដើបានដែរ អាស្រ័យលើស្ថានភាពកុមារក្នុងថ្នាក់របស់អ្នកដែរ។